ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ចិញ្ចឹមបង្កងអូស្ត្រាលីក្នុងស្រះ
## Red Claw Crayfish Farming in Pond



រៀបចំដោយ
**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**

ខែមិថុនា ឆ្នាំ២០២៣

023 220 811
023 220 810
012 847 387
#9-13, Street 7, Chaktomuk, Daun Penh, Phnom Penh | info@ardb.com.kh | www.ardb.com.kh

**មាតិកា**

**១-សេចក្តីផ្តើម** 1

**២-បច្ចេកទេសចិញ្ចឹមបង្កងអូស្ត្រាលី** 1

២.១. ការរៀបចំស្រះ 1

២.២. ការរៀបចំជម្រក 2

២.៣. គុណភាពទឹកក្នុងស្រះចិញ្ចឹម 2

២.៤. ការជ្រើសរើសកូនពូជ 2

២.៥. ដង់ស៊ីតេដាក់កូនបង្កងពូជចិញ្ចឹម 3

២.៦. ការលែងកូនបង្កងពូជ 3

២.៧. ការផ្តល់ចំណី 3

២.៨. ការគ្រប់គ្រងគុណភាពទឹក 4

២.៩. ការប្រមូលផល 5

**៣-គម្រោងនៃការចំណាយលើការចិញ្ចឹមបង្កងអូស្ត្រាលីក្នុងស្រះ** 5

៣.១. គម្រោងចិញ្ចឹមបង្កងសាច់ 5

៣.២. ចំណាយលម្អិតលើការចាប់ផ្តើមអាជីវកម្មដំបូង 6

៣.៣. ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹម១វគ្គ 7

៣.៤. ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់ និងទិន្នផល 8

**៤-ខ្សែច្រវាក់តម្លៃ** 8

**៥-ហានិភ័យ និងបញ្ហាប្រឈម** 8

**៦-សេចក្តីសន្និដ្ឋាន** 9

**ប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវ** 9

## ១-សេចក្តីផ្តើម

បង្កងទឹកសាបមួយប្រភេទដែលគេនិយមហៅថា “**បង្កងអូស្ត្រាលី** ” ឈ្មោះជាភាសាអង់គ្លេស Red Claw Crayfish និងឈ្មោះវិទ្យាសាស្ត្រ Cherax quadricarinatus មានដើមកំណើតមកពីភាគពាយ័ព្យនៃតំបន់ Queensland ប្រទេសអូស្ត្រាលី។ បង្កងនេះមានសម្បកពណ៌ខៀវភ្លឺរលោង ឬបៃតងត្នោត។ ឯបង្កងឈ្មោលមានពណ៌ក្រហមភ្លឺថ្លានៅត្រង់ចុងដង្កៀបរបស់វា។ បង្កងឈ្មោលមានទម្ងន់អតិបរិមារហូតដល់៥០០ក្រាម និងបង្កងញីមានទម្ងន់៤០០ក្រាម។ កូនបង្កងមានទម្ងន់តូចជាង២០-៣០ក្រាម។ គេអាចដឹងបង្កងញីឬឈ្មោលដោយសារការមើលលើដង្កៀបរបស់វា។

នៅក្នុងអំឡុងឆ្នាំ ២០១៩ អាជីវកម្មចិញ្ចឹមបង្កងអូស្ត្រាលីនៅកម្ពុជា បានចាប់ផ្តើមពេញនិយមខ្លាំងតាមរយៈការចិញ្ចឹមក្នុងអាងស៊ីម៉ងត៍ តង់ប្លាស្ទិក លូ និងក្រោយមកទើបមានការពង្រីកទៅចិញ្ចឹមក្នុងស្រះឬក្នុងស្រែសម្រាប់ផ្គត់ផ្គង់បង្កងពូជ និងសាច់ទៅទីផ្សារ ដែលអាចផ្តល់ទិន្នផលខ្ពស់ជាងការចិញ្ចឹមក្នុងអាងឬតង់ប្លាស្ទិក។ អាជីវកម្មចិញ្ចឹមបង្កងអូស្ត្រាលីមានតម្រូវការទីផ្សារល្អទាំងប្រភេទបង្កងសាច់ និងបង្កងពូជ ដោយសារមានមានការបញ្ជាទិញពីភោជនីយដ្ឋាន និងជាពិសេសកសិករបន្តការចិញ្ចឹមជាច្រើនកន្លែង ដែលធ្វើឱ្យមានការបញ្ជាទិញជាបន្តបន្ទាប់ ស្ទើរគ្រប់ខេត្តក្រុង នៅទូទាំងប្រទេសកម្ពុជា។

ដើម្បីឱ្យការចិញ្ចឹមបង្កងអូស្ត្រាលីទទួលបានជោគជ័យទាមទារឱ្យមានការរៀបចំស្រះ និងជម្រកឱ្យបានត្រឹមត្រូវ ដង់ស៊ីតេដាក់ចិញ្ចឹមឱ្យបានសមស្រប និងត្រូវជ្រើសរើសពូជល្អៗសម្រាប់ចិញ្ចឹម ការគ្រប់គ្រងគុណភាពទឹក ការផ្តល់ចំណីឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់។ ដើម្បីឱ្យបង្កងមានការលូតលាស់ធំធាត់លឿន កសិករចាំបាច់ត្រូវមានការអភិវឌ្ឍបច្ចេកទេសចិញ្ចឹម ឱ្យកាន់តែល្អប្រសើរឡើង។





## ២-បច្ចេកទេសចិញ្ចឹមបង្កងអូស្ត្រាលី

### ២.១. ការរៀបចំស្រះ÷

- តំបន់មានប្រភពទឹកពេញមួយឆ្នាំ ជាទឹកស្អាតមានកំហាប់អំបិលមិនលើសពី១០ភាគពាន់ គ្មានជាតិពុល និងមិនទទួលរងផលប៉ះពាល់ពីការប្រើប្រាស់ថ្នាំពុលកសិកម្ម និងកាកសំណល់ចេញពីរោងចក្រ។
- ជ្រើសរើសទីតាំងស្ងប់ស្ងាត់ ងាយស្រួលផ្គត់ផ្គង់ទឹក និងជម្រកការពារ
- មានផ្លូវគមនាគមន៍ និងអគ្គិសនីគ្រប់គ្រាន់ ជាពិសេសសម្រាប់ការចិញ្ចឹមទ្រង់ទ្រាយមធ្យម និងធំ

- ជាតំបន់ដីល្បាយដីឥដ្ឋ ឬខ្សាច់តិចតួច អាចរក្សាទឹកបានយូរ និងគ្មានជាតិជូរ
- ស្រះគួរមានទំហំចាប់ពី ១,០០០ម៉ែ២ឡើងទៅ និងជម្រៅចាប់ពី ១ ទៅ១.៥ម៉ែត្រ
- ជុំវិញស្រះត្រូវបាំងស័ង្កសីឬស្បៃក្រឡាល្អិតមានកម្ពស់០.៥ម៉ឡើង ដើម្បីការពារបង្កងវារចេញ និងសត្វខាងក្រៅចូល។
- ស្រះចិញ្ចឹមត្រូវរៀបចំប្រព័ន្ធបញ្ចេញបញ្ចូលទឹក ដើម្បីងាយស្រួលគ្រប់គ្រងទឹក និងចំណាយតិច
- ចំពោះស្រះចាស់ត្រូវបូមទឹកឱ្យរីងចាប់ត្រី និងសម្អាតកាកសំណល់ចេញពីស្រះឱ្យបានស្អាត
- បាចកំបោរសបរិមាណពី ៥-១០គ.ក/១០០ម៉ែ២ (ស្រះថ្មី) និង ១០-១៥គ.ក/១០០ម៉ែ២ (ស្រះចាស់)

**២.២. ការរៀបចំជម្រក÷**

- នៅបាតស្រះត្រូវរៀបចំជម្រកសិប្បនិម្មិត ដោយប្រើស្បៃជ័រ និងបង្គោលឈើ ឬឫស្សី ប្រក់ជារាងទឹករលក កម្ពស់ពី ២០-៣០សង់ទីម៉ែត្រ ពីបាតស្រះ ។
- ប្រើបំពង់ជ័រ ឬឫស្សី កាត់ជាកំណាត់ៗប្រវែងប្រមាណ ២០សង់ទីម៉ែត្រ ដាក់នៅបាតស្រះ



**២.៣. គុណភាពទឹកក្នុងស្រះចិញ្ចឹម÷**

- ជម្រៅទឹកក្នុងស្រះចន្លោះពី ០.៧-១.៥ម៉
- សីតុណ្ហភាពទឹកពី ២២-៣២អង្សាសេ
- កម្រិត pH ចន្លោះពី ៧-៨.៥
- សារធាតុរ៉ែចន្លោះពី ៣០០-៥០០

**២.៤. ការជ្រើសរើសកូនពូជ÷**

គុណភាពកូនពូជ គឺជាកកត្តាសំខាន់នៅក្នុងការចិញ្ចឹមទទួលបានទិន្នផលខ្ពស់។ កសិករត្រូវជ្រើសរើសកូនបង្កងពូជដែលមានគុណភាពល្អ ស្របតាមគោលការណ៍បច្ចេកទេសដូចខាងក្រោម÷

- ជ្រើសរើសកូនពូជដែលមានកម្លាំងមាំមួន រហ័សរហួន រូបរាងស្អាតល្អ មិនមានរបួសស្នាម និងមិនមានជំងឺ ។
- កូនពូជមានប្រវែងចាប់ពី ៣សង់ទីម៉ែត្រឡើងទៅ និងមានទំហំប៉ុនៗគ្នាល្អ
- កូនពូជមានសុខភាពល្អ មានពុកមាត់ ជើង និងដង្កៀបគ្រប់គ្រាន់

- កូនពូជមានប្រភពច្បាស់លាស់មកពីកសិដ្ឋាន ដែលមានការកត់ត្រាច្បាស់លាស់ កេរ្តិ៍ឈ្មោះល្អ និងរៀបចំស្អាត។




**២.៥. ដង់ស៊ីតេដាក់កូនបង្កងពូជចិញ្ចឹម÷**

ចំនួនកូនបង្កងដាក់ចិញ្ចឹម អាស្រ័យលើដំណាក់កាលលូតលាស់ធំធាត់នៃកូនបង្កងពូជ ដែលគោលបំណងនៃការចិញ្ចឹមសម្រាប់ផ្គត់ផ្គង់ទីផ្សារមានដូចខាងក្រោម÷

- កូនបង្កងចុះដើរ រហូតអាយុ ៤៥ថ្ងៃ ដាក់ចិញ្ចឹមចន្លោះពី ២០០-៣០០កូន/ម៉$^{២}$
- បង្កងចិញ្ចឹមយកសាច់រយៈពេល ១២០ថ្ងៃ ដាក់ចិញ្ចឹមចន្លោះពី ១០-១២ក្បាល/ម៉$^{២}$
- បង្កងចិញ្ចឹមយកសាច់រយៈពេល ១៥០ថ្ងៃ ដាក់ចិញ្ចឹមចន្លោះពី ៨-១០ក្បាល/ម៉$^{២}$
- បង្កងចិញ្ចឹមយកសាច់រយៈពេល ១៨០ថ្ងៃ ដាក់ចិញ្ចឹមចន្លោះពី ៦-៨ក្បាល/ម៉$^{២}$ ។

**២.៦. ការលែងកូនបង្កងពូជ÷**

ត្រូវលែងកូនបង្កងនៅពេលអាកាសធាតុត្រជាក់ ជាពិសេសពេលព្រឹក។ មុនពេលលែងកូនបង្កង ត្រូវពិនិត្យគុណភាពទឹកក្នុងស្រះជាមុនសិន ជាពិសេសសារធាតុរ៉ែ និងកម្រិតpHមានលក្ខខណ្ឌសមស្រប សម្រាប់កូនបង្កង។ ក្នុងករណីកូនបង្កងពូជដឹកជញ្ជូនដោយប្រើកេសស្នោ ត្រូវបើកគម្របហើយបណ្តែតកេសស្នោលើទឹកស្រះរយៈពេលពី ២០-៣០នាទី ក្រោយមកយកទឹកក្នុងស្រះនោះចាក់ចូលកេសស្នោត្រឹមខ្នងកូនបង្កង និងបន្តបណ្តែតរយៈពេល ២០-៣០នាទីទៀត ធ្វើយ៉ាងនេះដើម្បីឱ្យសីតុណ្ហភាពទឹកក្នុងកេសនិងស្រះប្រហាក់ប្រហែលគ្នា ទើបលែងកូនបង្កងចូលទៅក្នុងស្រះតាមសម្រួល។

**២.៧. ការផ្តល់ចំណី÷**

បរិមាណចំណីត្រូវផ្តល់ឱ្យកូនបង្កងស៊ីសមល្មម ជៀសវាងផ្តល់ចំណីលើស ពីព្រោះចំណីដែលនៅសល់អាចបំលែងទៅជាសារធាតុពុល បង្កឱ្យបង្កងពិបាកសក និងលូតលាស់មិនសូវល្អ។ បង្កងអូស្ត្រាលីស៊ីចំណីចម្រុះមាន ប្រភេទសាច់(ខ្យង ក្តាម កំពិស ត្រី ជ្រូក មាន់ ទា គោ ស្បែកគោ...) ប្រភេទបន្លែផ្លែឈើ(ល្ពៅ ត្រឡាច សណ្តែកបាយ សណ្តែកសៀង ល្ហុង ស្វាយ ពោត...) និងរុក្ខជាតិទឹក(សារ៉ាយ ចកអាសូឡា កំប្លោក...)។

ប្រភេទចំណីសំខាន់ៗសម្រាប់អាជីវកម្មចិញ្ចឹមបង្កងមានបីប្រភេទ រួមមាន÷

**-ប្រភេទចំណីគ្រាប់÷** ជាចំណីសម្រេចពីរោងចក្រ មានសមាសធាតុផ្សំគ្រប់គ្រាន់ តាមតម្រូវការ និងមានប្រូតេអ៊ីនខ្ពស់ អាចធ្វើឱ្យបង្កងធំធាត់លឿន។

**-ប្រភេទចំណីផ្សំ÷** ជាប្រភេទចំណីដែលកសិករអាចរកបាននៅតាមមូលដ្ឋាន រួមមាន ចុងអង្ករ សណ្តែកសៀង កន្ទក់ ល្ពៅ ត្រឡាច ដំឡូងជ្វា ពោត ម្សៅត្រីឬត្រីនុយ ដោយលាយបញ្ចូលគ្នា រួចចម្អិនឱ្យឆ្អិនមុនពេលឱ្យបង្កងស៊ី។ ចំណីផ្សំគួរមានលាយវីតាមីនព្រីមិច និងសារធាតុជួយរំលាយអាហារ ដើម្បីជួយដល់ការលូតលាស់លឿន និងបង្ការជំងឺផ្សេងៗ។

**-ប្រភេទចំណីស្រស់÷** មានដូចជា ត្រីជី កូនត្រីល្អិត កំពឹស ក្តាម ខ្យង សត្វល្អិត កាកសំណល់ផ្ទះបាយ រោងចក្រ និងកាកសំណល់សត្តឃាតដ្ឋាន។

កសិករគួរបង្កើតចំណីធម្មជាតិបន្ថែម ដោយដាក់ជីបង្កើតចំណីធម្មជាតិ (ជី លាមកគោ មាន់ ទា...) បរិមាណពី ២៥-៣០គ.ក/១០០ម៉$^{២}$ និងក្នុងដំណាក់កាលរៀបចំស្រះ ឬអាចប្រើជីអ៊ុយរ៉េ ៣ក្រាម/ម៉$^{៣}$ និងជីដេអាប៉េ ២ក្រាម/ម៉$^{៣}$ ក្រោយពេលបញ្ចូលទឹករួច និងក្នុងពេលកំពុងចិញ្ចឹម ។

**តារាងផ្តល់ចំណីដល់បង្កងអូស្ត្រាលី÷**

| រយៈពេលចិញ្ចឹម (ថ្ងៃ) | ទម្ងន់បង្កងមធ្យម (ក្រាម) | ភាគរយចំណី (%) | ចំនួនដងផ្តល់ចំណី |
|---|---|---|---|
| 31-60 | 10-20 | 1.5 | 2 |
| 60-90 | 20-40 | 1 | 2 |
| 91-120 | 40-60 | 0.8 | 1 |
| 121-150 | 60-80 | 0.7 | 1 |
| 151-180 | 80-100 | 0.6 | 1 |
| 181 ឡើងទៅ | 101 ឡើង | 0.5 | 1 |






**២.៨.ការគ្រប់គ្រងគុណភាពទឹក÷**

បង្កងលូតលាស់ និងធំធាត់អាស្រ័យទៅលើការសក ដែលជាកត្តាសំខាន់និងចាំបាច់បំផុត។ ដើម្បីឱ្យបង្កងសកបាន ត្រូវគ្រប់គ្រងគុណភាពទឹកស្រះឱ្យបានល្អ។

ខាងក្រោមនេះ គឺជាវិធីសាស្ត្រមួយចំនួនក្នុងការគ្រប់គ្រងគុណភាពទឹកស្រះឱ្យបានល្អ÷

-**ការពិនិត្យ និងតាមដានគុណភាពទឹក÷** ត្រូវពិនិត្យជាប្រចាំនូវកត្តាសំខាន់ៗនៃគុណភាពទឹករួមមាន កម្រិត(pH) កម្រិតសារធាតុរ៉ែ (Alkalinity) កំហាប់អំបិល បរិមាណអុកស៊ីសែនក្នុងទឹក កម្រិតរឹងនៃទឹក ($CaCo_3$) នីទ្រីត ឬកម្រិតអាម៉ូញាក់ ជាដើម។

-**ការផ្លាស់ប្តូរទឹក÷** នៅខែដំបូងមិនចាំបាច់ផ្លាស់ប្តូរទឹកទេ ព្រោះលាមករបស់បង្កងនៅបាតស្រះមានបរិមាណតិចតួចនៅឡើយ។ ខែទី២ ត្រូវពិនិត្យគុណភាពទឹក និងអាចប្តូរបរិមាណទឹកពី ៣០-៥០% នៃទឹកក្នុងស្រះ។ ការប្តូរទឹកនេះគឺត្រូវបូមយកលាមកបង្កង និងកាកសំណល់ផ្សេងៗទៀតចេញពីផ្នែកបាតស្រះនិងបញ្ចូលទឹកថ្មីវិញនៅផ្នែកខាងលើនៃផ្ទៃស្រះដោយមានប្រើស្បៃច្រោះទឹកដែលបានបង្ហូរចូលនោះ។

-**ការថែទាំបង្កងក្នុងស្រះ÷** ត្រូវតាមដានសកម្មភាពបង្កង បើឃើញបង្កងវារចេញពីស្រះខុសធម្មតា ត្រូវធ្វើការត្រួតពិនិត្យគុណភាពទឹកស្រះភ្លាម និងមានវិធានការកែលម្អទឹកឱ្យបានទាន់ពេលវេលា។ នៅពេលព្រឹកព្រលឹម ប្រសិនបើឃើញបង្កងប្រមូលផ្តុំគ្នានៅជ្រុងស្រះ នោះបញ្ជាក់ថាទឹកស្រះខ្វះខ្យល់អុកស៊ីសែន ដូច្នេះត្រូវផ្លាស់ប្តូរទឹកជាបន្ទាន់។ យើងត្រូវត្រួតពិនិត្យស្រះជារៀងរាល់ថ្ងៃ ដូចជានៅមាត់ស្រះ ទ្វារទឹក និងត្រូវកម្ចាត់សត្វចង្រៃដូចជា កណ្តុរ ពស់ កង្កែប ក្តាម ជាដើម។ល។

### ២.៩.ការប្រមូលផល÷

ចិញ្ចឹមបានរយៈពេល៤-៦ខែ បង្កងមួយចំនួនចាប់ផ្តើមមានទម្ងន់ចន្លោះពី២០-២៥ក្បាល/គីឡូក្រាម កសិករអាចចាប់ផ្តើមប្រមូលផលរំលស់កូនបង្កង ដែលមានទំហំធំស្របតាមតម្រូវការទីផ្សារ ដោយប្រើលបមុខ១០០ ហើយរក្សាទុកកូនបង្កងដែលមានទំហំតូចៗចិញ្ចឹមបន្តឱ្យមានការលូតលាស់ធំធាត់លឿនជាងមុន។ ការប្រមូលផលសរុប នៅដំណាក់កាលចុងក្រោយគឺត្រូវធ្វើឡើងនៅខែទី១២ ដោយបូមទឹកចេញឱ្យអស់ពីស្រះ និងប្រមូលចាប់កូនបង្កងទាំងស្រុងតែម្តង។ បង្កងត្រូវបានចាប់លាងសម្អាតនិងដាក់ក្នុងធុងស្នោរ ដោយមានចោះប្រហោងខ្យល់សម្រាប់បង្កងដកដង្ហើម។

## ៣-គម្រោងនៃការចំណាយលើការចិញ្ចឹមបង្កងអូស្ត្រាលីក្នុងស្រះ÷

### ៣.១.គម្រោងចិញ្ចឹមបង្កងសាច់÷ (បទពិសោធន៍របស់កសិករនៅខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ)

- ទំហំស្រះ ÷ ១៥,០០០ម៉$^{៣}$ (បណ្តោយ២០០ម៉ ទទឹង៥០ម៉ ជម្រៅទឹក១.៥ម៉)
- ចំនួនកូនបង្កងពូជ/វគ្គ ÷ ១០០,០០០កូន (ដង់ស៊ីតេដាក់ចិញ្ចឹម ១០ក្បាល/ម៉$^{២}$)
- ប្រភពកូនពូជ ÷ ផលិតក្នុងកសិដ្ឋានផ្ទាល់ (តម្លៃទីផ្សារ ៥០០៛/កូន)
- ចំនួនវគ្គចិញ្ចឹម/ឆ្នាំ ÷ ១វគ្គ/ឆ្នាំ
- រយៈពេលចិញ្ចឹម ÷ ១២ខែ/វគ្គ
- ការផ្តល់ចំណី ÷ ចំណីផ្សំដោយខ្លួនឯង និងចំណីធម្មជាតិក្នុងតំបន់

- អត្រាបាត់បង់ ÷ ៥០% (អាស្រ័យលើសុខភាពកូនពូជ និងការថែទាំ)
- ទិន្នផល ÷ ជាមធ្យម ២,១៥០គ.ក/វគ្គ
- ទីផ្សារ ÷ មានអតិថិជនគ្រប់ខេត្តក្រុងទូទាំងប្រទេស
- តម្លៃទីផ្សារ ÷ ពី៤៨,០០០-៧២,០០០រៀល/គ.ក អាស្រ័យលើទំហំបង្កង (គិតជាមធ្យម ៥០,០០០ រៀល/គ.ក)
- តម្រូវការទុន ÷ សម្រាប់ការចាប់ផ្តើមអាជីវកម្មដំបូងគឺត្រូវការដើមទុនប្រមាណ **១២១,៣៣១,០០០រៀល** ក្នុងនោះ÷

| ទុនវិនិយោគសម្រាប់ជីកស្រះ ប្រព័ន្ធទឹក និងបំពាក់សម្ភារៈ (រៀល) | ទុនសម្រាប់ដំណើរការចិញ្ចឹមបង្កងអូស្ត្រាលី (រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|
| **៦១,៦៨០,០០០** | **៦០,៤១៦,០០០** | **១២២,០៩៦,០០០** |

## ៣.២. ចំណាយលម្អិតលើការចាប់ផ្តើមអាជីវកម្មដំបូង÷

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| **ចំណាយសរុប ក+ខ** | | | | | **122,096,000** |
| **ក-ចំណាយប្រែប្រួល** | | | | | **60,416,000** |
| 1 | កូនពូជបង្កងអូស្ត្រាលី (១០ក្បាល/ម៉$^{២}$) | ក្បាល | 100,000 | 500 | 50,000,000 |
| 2 | ចំណីផ្សំ (ល្ពៅ សណ្តែកបាយ ពោត ត្រី ...) | គ.ក | 7,200 | 1,000 | 7,200,000 |
| 3 | កំបោរស | គ.ក | 200 | 1,500 | 300,000 |
| 4 | កម្លាំងពលកម្ម (ធ្វើការ ៣ម៉/ថ្ងៃ) | ខែ | 12 | 200,000 | 2,400,000 |
| 5 | ថ្លៃប្រេងឥន្ធនៈ | លីត្រ | 120 | 4,300 | 516,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | **61,680,000** |
| 1 | ស្រះចិញ្ចឹម (២០០ម x ៥០ម x១.៥ម) | ម៉ែត្រគីប | 15,000 | 4,000 | 60,000,000 |
| 2 | ស្បៃរបាំងជុំវិញស្រះ និងជម្រកសិប្បនិម្មិត | ស្រះ | 1 | 400,000 | 400,000 |
| 3 | ម៉ាស៊ីនបូមទឹក (សាំង) | គ្រឿង | 1 | 480,000 | 480,000 |
| 4 | ទុយោបូមទឹក (ទន់) | ម៉ែត្រ | 100 | 4,000 | 400,000 |
| 5 | ឧបករណ៍ពិនិត្យគុណភាពទឹក | ឈុត | 1 | 200,000 | 200,000 |
| 6 | កញ្ច្រែងដាក់ចំណី | កញ្ច្រែង | 10 | 20,000 | 200,000 |
| 7 | លបមុខ១០០ (សម្រាប់ប្រមូលផល) | លប | 4 | 80,000 | 320,000 |
| 8 | ថ្នាំងចម្អិនចំណី និងសម្ភារៈជំនួយផ្សេងៗ | ឈុត | 1 | 200,000 | 200,000 |

### ៣.៣. ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹមបង្កងក្នុង ១វគ្គ÷

-ការវិភាគសេដ្ឋកិច្ចសម្រាប់ការចិញ្ចឹមបង្កងអូស្រ្តាលីនៅក្នុងស្រះ មានទំហំ ១០,០០០ម៉$^{២}$ (២០០ម៉ x ៥០ម៉) ដោយដាក់កូនបង្កងពូជសរុបចំនួន **១០០,០០០ក្បាល** ចិញ្ចឹមរយៈពេល ១២ខែ(ក្នុង១វគ្គ) ក្រោយកាត់រំលស់លើការចំណាយថេរ និងការចំណាយលើការផលិត÷

| ចំណាយសរុប (រៀល) | ចំណូលជាមធ្យម (រៀល) | ចំណេញសរុប (រៀល) |
|---|---|---|
| **៦៤,២៥៧,៣៣៣** | **១០៧,៥០០,០០០** | **៤៣,២៤២,៦៦៧** |

**-តារាងចំណូល-ចំណាយលម្អិត÷**

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | ចំនួនវដ្ត រំលស់ | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|---|
| **ចំណូលពីការលក់** | | | | | | |
| 1 | ចំណូលជាមធ្យមពីការលក់ | គ.ក | 2,150 | 50,000 | | **107,500,000** |
| **ចំណាយសរុប ក+ខ** | | | | | | **64,305,333** |
| **ក-ការចំណាយប្រែប្រួល** | | | | | | **60,416,000** |
| 1 | កូនពូជបង្កងអូស្រ្តាលី (១០ក្បាល/ម$^{២}$) | ក្បាល | 100,000 | 500 | | 50,000,000 |
| 2 | ចំណីផ្សំ (ល្ពៅ សណ្តែកបាយ ពោត ត្រី...) | គ.ក | 7,200 | 1,000 | | 7,200,000 |
| 3 | កំបោរស | គ.ក | 200 | 1,500 | | 300,000 |
| 4 | កម្លាំងពលកម្ម (ធ្វើការ ៣ម៉/ថ្ងៃ) | ខែ | 12 | 200,000 | | 2,400,000 |
| 5 | ថ្លៃប្រេងឥន្ធនៈ | លីត្រ | 120 | 4,300 | | 516,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **3,889,333** |
| 1 | ស្រះចិញ្ចឹម (២០០ម៉ x ៥០ម៉ x១.៥ម៉) | ម៉$^{៣}$ | 15,000 | 4,000 | 20 | 3,000,000 |
| 2 | ស្បៃរបាំងជុំវិញស្រះ និងជម្រកសិប្បនិម្មិត | ស្រះ | 1 | 400,000 | 2 | 200,000 |
| 3 | ម៉ាស៊ីនបូមទឹក (សាំង) | គ្រឿង | 1 | 480,000 | 5 | 96,000 |
| 4 | ទុយោបូមទឹកទន់ | ម៉ែត្រ | 100 | 4,000 | 3 | 133,333 |
| 5 | ឧបករណ៍ពិនិត្យគុណភាពទឹក | ឈុត | 1 | 200,000 | 2 | 100,000 |
| 6 | កញ្ច្រែងដាក់ចំណី | កញ្ច្រែង | 10 | 20,000 | 2 | 100,000 |
| 7 | លបមុខ១០០ (សម្រាប់ប្រមូលផល) | លប | 4 | 80,000 | 2 | 160,000 |
| 8 | ឆ្នាំងចម្អិតចំណី និងសម្ភារៈជំនួយផ្សេងៗ | ឈុត | 1 | 200,000 | 2 | 100,000 |
| ចំណេញសរុបក្រោយពីកាត់ចំណាយ | | | | | | **43,194,667** |
| ចំណាយថ្លៃដើមក្នុងការចិញ្ចឹមបង្កងក្នុង១ គ.ក | | | | | | **29,909** |
| ចំណេញពីការផលិតបង្កងសាច់ ១ គ.ក | | | | | | **20,091** |

### ៣-៤-ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់ និងទិន្នផល÷

តាមរយៈបទពិសោធន៍របស់កសិករ ដែលក្រុមការងារបានសិក្សាផ្ទាល់ ការចិញ្ចឹមបង្កងអូស្ត្រាលីមានអត្រាបាត់បង់ខ្ពស់រហូតដល់ ៥០% ដោយសារកត្តាមួយចំនួនដូចជា បង្កងងាប់ដោយសារកម្រិតជាតិពុលនៅក្នុងទឹក ការស៊ីគ្នានៅក្នុងអំឡុងពេលបង្កងសក និងកត្តាសត្វចង្រៃផ្សេងៗ រួមមាន ត្រីដែលនៅសល់ក្នុងស្រះចិញ្ចឹម កង្កែប ក្តាម និងសត្វស្លាប ដែលនាំឱ្យទិន្នផលសរុបមានការប្រែប្រួល។

| ទិន្នផលទទួលបាន (គ.ក) | តម្លៃលក់ជាមធ្យម (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | កំណត់សម្គាល់អំពីទិន្នផល |
|---|---|---|---|---|---|
| 2,150 | 72,000 | 154,800,000 | 64,305,333 | 90,494,667 | ករណីកូនបង្កងមានអត្រាបាត់បង់ ៥០% |
| | 60,000 | 129,000,000 | 64,305,333 | 64,694,667 | |
| | 50,000 | 107,500,000 | 64,305,333 | 43,194,667 | |
| 2,580 | 72,000 | 185,760,000 | 64,305,333 | 121,454,667 | ករណីកូនបង្កងមានអត្រាបាត់បង់ ៤០% |
| | 60,000 | 154,800,000 | 64,305,333 | 90,494,667 | |
| | 50,000 | 129,000,000 | 64,305,333 | 64,694,667 | |
| 2,795 | 72,000 | 201,240,000 | 64,305,333 | 136,934,667 | ករណីកូនបង្កងមានអត្រាបាត់បង់ ៣៥% |
| | 60,000 | 167,700,000 | 64,305,333 | 103,394,667 | |
| | 50,000 | 139,750,000 | 64,305,333 | 75,444,667 | |

## ៤-ខ្សែច្រវ៉ាក់តម្លៃ

**កសិករ** ÷ ករណីលក់បានតម្លៃ ៥០,០០០៛/គ.ក តម្លៃថ្លៃដើមផលិត ២៩,៩០៩៛/គ.ក អាចចំណេញបាន ២០,០៩១៛/គ.ក ។

↓

**ឈ្មួញកណ្តាល**÷ លក់បានតម្លៃ ៦០,០០០៛/គ.ក ថ្លៃដឹកជញ្ជូន លើកដាក់ កាត់ការខូចខាត ២,០០០៛/គ.ក អាចចំណេញបាន ៨,០០០៛/គ.ក ។

↓

**អ្នកលក់រាយ** ÷ លក់បានតម្លៃ ៧២,០០០៛/គ.ក ថ្លៃដឹកជញ្ជូន លើកដាក់ និងថែរក្សា កាត់ការខូចខាត ២,០០០៛/គ.ក អាចចំណេញបាន ១០,០០០៛/គ.ក ។

## ៥-ហានិភ័យ និងបញ្ហាប្រឈម

តាមការសិក្សាផ្ទាល់នៅកសិដ្ឋានចិញ្ចឹមបង្កងអូស្ត្រាលី កសិករតែងជួបនូវហានិភ័យផលិតកម្មដូចខាងក្រោម÷

-ការរៀបចំស្រះមិនបានត្រឹមត្រូវ និងជម្រកសិប្បនិម្មិតមិនគ្រប់គ្រាន់តាមបច្ចេកទេស នាំឱ្យមានការបាត់បង់កូនបង្កងក្នុងអំឡុងពេលសក បណ្តាលមកពីកូនបង្កងមិនទាន់សកស៊ីកូនបង្កងកំពុងសក។ កសិករត្រូវរៀបចំជម្រកសិប្បនិម្មិតឱ្យបានត្រឹមត្រូវ និងសមស្របតាមបរិមាណកូនបង្កងដែលបានដាក់ចិញ្ចឹម។

-គុណភាពទឹកមិនសមស្រប÷ ការសករបស់កូនបង្កងមិនល្អ នាំឱ្យការលូតលាស់ និងធំធាត់របស់បង្កងមិនស្មើគ្នា និងយឺតយ៉ាវ។ កសិករត្រូវពិនិត្យគុណភាពទឹកជាប្រចាំអំពីកម្រិតប៉េហាស់ (pH) សារធាតុរ៉ែ (Alkalinity) កំហាប់អំបិល បរិមាណអុកស៊ីសែនក្នុងទឹក កម្រិតរឹងនៃទឹក ($CaCo_3$) កម្រិតអាម៉ូញាក់។

-ពេលមានភ្លៀងខ្លាំងឬច្រើនថ្ងៃជាប់ៗគ្នា នឹងធ្វើឱ្យទឹកក្នុងស្រះមានការប្រែប្រួលខ្លាំងកម្រិតpH នាំឱ្យកូនបង្កងអន់ស៊ីចំណី និងអាចបង្ករឱ្យមានជាជំងឺរលាក។ អ្នកចិញ្ចឹមត្រូវពិនិត្យ និងតាមដានជាប្រចាំនូវកម្រិត pH និងសីតុណ្ហភាពទឹក ទើបអាចដោះស្រាយបានទាន់ពេលវេលា។

## ៦-សេចក្តីសន្និដ្ឋាន

ការចិញ្ចឹមបង្កងអូស្ត្រាលីនៅក្នុងស្រះគឺជាអាជីវកម្មមួយល្អ អាចចិញ្ចឹមបានពេញមួយឆ្នាំ។ ការចំណាយតម្លៃថ្លៃដើមផលិតទាបប្រមាណ ២៩,៩០០រៀល/គ.ក ចំណែកតម្លៃបង្កងអូស្ត្រាលីសាច់នៅលើទីផ្សារមានតម្លៃចន្លោះពី ៤៨,០០០-៦០,០០០រៀល/គ.ក អាស្រ័យលើទំហំបង្កង ដែលកសិករអាចទទួលបានផលចំណេញបានល្អប្រសើរ។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការចិញ្ចឹមបង្កងអូស្ត្រាលីទទួលបានទិន្នផលខ្ពស់ កសិករគួរយកចិត្តទុកដាក់លើកត្តាសំខាន់ៗមួយចំនួន ដូចជា ត្រូវរៀបចំស្រះឱ្យបានត្រឹមត្រូវ និងជម្រកសិប្បនិម្មិតឱ្យបានគ្រប់គ្រាន់សម្រាប់ពេលបង្កងសក និងអាចគេចពីសត្វចង្រៃផ្សេងៗ ត្រូវពិនិត្យគុណភាពទឹកជាប្រចាំនូវកម្រិតប៉េហាស់ សីតុណ្ហភាពទឹក សារធាតុរ៉ែ(Alkalinity) កំហាប់អំបិល បរិមាណអុកស៊ីសែនក្នុងទឹក កម្រិតរឹងនៃទឹក ($CaCo_3$) កម្រិតអាម៉ូញាក់ ដើម្បីអាចទប់ស្កាត់បញ្ហាកើតមានឡើងបានទាន់ពេលវេលា។

### ប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវ÷

១-កសិដ្ឋានចិញ្ចឹមបង្កងអូស្ត្រាលីនៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

២-បច្ចេកទេសចិញ្ចឹមបង្កងតាមគេហទំព័រ Facebook និង Telegram មួយចំនួន÷

-Telegram: ដៃគូបង្កងអូស្ត្រាលីធម្មជាតិ *https://t.me/Lobster_Learn*

- *https://www.facebook.com/CrayfishPnomKromSiemReap/*
- *https://www.facebook.com/groups/662693717907371/learning_content*
- *https://www.fao.org/fishery/en/culturedspecies/search*
- *https://thefishsite.com/articles/cultured-aquatic-species-red-claw-crayfish*
- *https://www.facebook.com/profile.php?id=100059972016307&sk=likes*
- *https://www.youtube.com/channel/UCjkUGYzR2hBhfcKR92tCTOw*
- *https://t.me/damnakkey_crayfish*